ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញស្តីពី

# ក្របខ័ណ្ឌអភិវឌ្ឍន៍ផែនការសកម្មភាពយេនឌ័រ របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤)

ដោយកញ្ញា **ខុំ ផានិត** ប្រធានការិយាល័យសវនកម្មទី២
**នាយកដ្ឋានសវនកម្មទី១**

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

# មាតិកា


I. សេចក្តីផ្តើម

II. ក្របខ័ណ្ឌអភិវឌ្ឍន៍ផែនការសកម្មភាព

III. គោលបំណង គោលដៅ

IV. ក្របខ័ណ្ឌដឹកនាំ ក្របខ័ណ្ឌអនុវត្ត និងធនធានមនុស្ស

V. បញ្ហាប្រឈម និងដំណោះស្រាយ

VI. ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុង

# I. សេចក្ដីផ្ដើម

❖ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្ដេជ្ញាចិត្តខ្ពស់លើ÷

១ ការលើកកម្ពស់សមភាពយេនឌ័រ

២ ផ្ដល់ភាពអង់អាចដល់ស្ត្រី

៣ ដាក់ចេញនូវវិធានការអនុវត្តច្បាប់ គោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤

# I. សេចក្ដីផ្ដើម (ត)

❖ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវ *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤* ដើម្បីកំណើនការងារសមធមិ និងប្រសិទ្ធភាពកសាងមូលដ្ឋានឆ្ពោះទៅសម្រេច ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ រួមទាំងការពង្រឹងលើកកម្ពស់ សមភាពយេនឌ័រក្នុងមុំទី៤ នៃចតុកោណទី១ ស្ដីពីការអភិវឌ្ឍធនធានមនុស្សក្នុងការពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិដោយកំណត់យុទ្ធសាស្ត្រសំខាន់ៗដើម្បីពន្លឿននូវសមភាពយេនឌ័រ។


រាជរដ្ឋាភិបាលកម្ពុជា

«យុទ្ធសាស្ត្រចតុកោណ»

ដើម្បីកំណើន ការងារ សមធមិ និង ប្រសិទ្ធភាព :
កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០
ដំណាក់កាលទី ៤
របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា

ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៨


«យុទ្ធសាស្ត្រចតុកោណ»

ដើម្បីកំណើន ការងារ សមធមិ និង ប្រសិទ្ធភាព :
កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០
ដំណាក់កាលទី ៤
របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា

ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៨

# I. សេចក្តីផ្តើម (ត)

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រង លើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។
- គ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់និងសហការ ចូលរួមបំពេញបេសកកម្មរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីជំរុញការអនុវត្ត សិទ្ធិ ការលើកកម្ពស់តួនាទីស្រ្តី និងការវិនិយោគលើសមភាពយេនឌ័រតាមរយៈការពង្រីកភាពជាដៃគូររវាងស្ថាប័នពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

# I. សេចក្តីផ្តើម (ត)




- ឆ្លើយតបទៅនឹងការបំពេញបេសកកម្មខាងលើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំជាផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យហិរញ្ញវត្ថុរយៈពេល ៥ ឆ្នាំ ២០០៨-២០១២ នឹងបន្តអនុវត្តរហូតដល់ឆ្នាំ ២០១៩។ នៅឆ្នាំ២០២០ ក្រុមការងារបញ្ជ្រាបយេនឌ័របានបន្តរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ ២០២០-២០២៣។

# I. សេចក្តីផ្តើម (ត)

- គ្រប់បណ្តាអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** ក៏ដូចជាអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** មានកាតព្វកិច្ចត្រូវរៀបចំនូវរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនលេខាធិការដ្ឋានក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។





# I. សេចក្តីផ្តើម (ត)

❖ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានយកចិត្តទុកដាក់ និងសហការចូលរួមបំពេញបេសកកម្មរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជំរុញ ការអនុវត្តសិទ្ធិ ការលើកកម្ពស់តួនាទីស្ត្រី និងការវិនិយោគលើសមភាពយេនឌ័រតាមរយៈការបង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈ ការទទួលបានការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាដើម។





# II. ក្របខ័ណ្ឌអភិវឌ្ឍន៍ផែនការសកម្មភាព

- អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានរៀបចំ ***ផែនការសកម្មភាពយេនឌ័ររបស់អង្គភាព*** សវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) ដោយផ្អែកលើមូលដ្ឋានចំនួន ២ គឺ÷
  - ផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២០-២០២៣ និង
  - *ផែនការសកម្មភាពបីឆ្នាំរំកិល២០២២-២០២៤។*






# III. គោលបំណង គោលដៅ

## ១.គោលបំណង

❖ ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) ត្រូវបាន រៀបចំឡើងក្នុងគោលបំណង÷

- ➢ ចូលរួមចំណែកលើកកម្ពស់ការអនុវត្តសិទ្ធិស្ត្រី និង
- ➢ លើកកម្ពស់សមត្ថភាពសមភាពយេនឌ័រក្នុងអង្គភាពសវនកម្មផ្ទៃក្នុងប្រកបដោយសមធមិស្រប តាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២០-២០២៣ ក៏ដូចជាផែនការសកម្មភាពបីឆ្នាំរំកិល ២០២២-២០២៤ របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ។



# III. គោលបំណង គោលដៅ (ត)

## ២. គោលដៅ

- ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) នេះ មានគោលដៅ៖
  - ពង្រឹងភាពអង់អាចរបស់ស្ត្រី
  - លើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច
  - ការបង្កើនចំនួនមន្ត្រីជាស្ត្រីក្នុងអង្គភាព
  - ការពង្រឹងសមត្ថភាពវិជ្ជាជីវៈ
  - ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និង
  - លើកកម្ពស់តួនាទីនៅគ្រប់កម្រិតក្នុងអង្គភាពសវនកម្មផ្ទៃក្នុង។



# IV. ក្របខ័ណ្ឌដឹកនាំ ក្របខ័ណ្ឌអនុវត្ត និងធនធានមនុស្ស

## ១. ក្របខ័ណ្ឌដឹកនាំ

- គ្រប់បណ្តាអង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារត្រូវមានសមាសភាពតំណាងនៅក្នុងក្រុមការងារបញ្ញោបយេនឌ័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលហៅកាត់ថា **ក.ប.យ.**។
- អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ក៏ត្រូវមានសមាសភាពនៅក្នុងក្រុមការងារ **ក.ប.យ.** នេះដែរ។
- **ក.ប.យ.** ជាសេនាធិការលើការងារបញ្ញោបយេនឌ័រដែលមានប្រធានមួយរូបមានឋានៈជារដ្ឋលេខាធិការ អនុប្រធានមួយចំនួន និងសមាជិកដែលមកពីគ្រប់អង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



# IV. ក្របខ័ណ្ឌដឹកនាំ ក្របខ័ណ្ឌអនុវត្ត និងធនធានមនុស្ស (ត)

## ២. ក្របខ័ណ្ឌអនុវត្ត

- ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបានប្រសិទ្ធភាពខ្ពស់ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានរៀបចំ *ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤)*។



# IV. ក្របខ័ណ្ឌដឹកនាំ ក្របខ័ណ្ឌអនុវត្ត និងធនធានមនុស្ស (ត)

## ៣.ធនធានមនុស្ស

- នាពេលបច្ចុប្បន្នអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** មានមន្ត្រីជាស្ត្រីចំនួន ១១រូប÷
  - មន្ត្រីរាជការចំនួន ០១ រូប មានតួនាទីជាប្រធានការិយាល័យ
  - មន្ត្រីលក្ខន្តិកៈចំនួន ១០ រូប ដែលក្នុងនោះមាន ០៣ រូប មានតួនាទីជាអនុប្រធានការិយាល័យ។



មន្ត្រីរាជការ



មន្ត្រីលក្ខន្តិកៈ

# V. បញ្ហាប្រឈម និងដំណោះស្រាយ

## ក. បញ្ហាប្រឈម

- ចំនួនមន្ត្រីជាស្ត្រីនៅមានកម្រិត
- សមាសភាពមន្ត្រីជាស្ត្រីដែលមានតួនាទីក្នុងជួរថ្នាក់ដឹកនាំនៅមានចំនួនតិចតួច
- ចំណេះដឹង និងជំនាញសវនកម្មនៅមានកម្រិត
- ភាពអង់អាចក្លាហានរបស់មន្ត្រីជាស្ត្រីនៅមានកម្រិត
- ការយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិទូទៅពាក់ព័ន្ធការការពារផលប្រយោជន៍របស់ស្ត្រីនៅមានកម្រិត។






# V. បញ្ហាប្រឈម និងដំណោះស្រាយ (ត)

## ២. ដំណោះស្រាយ

➢ ផ្តើមចេញពីបញ្ហាប្រឈមខាងលើក៏ដូចជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក្នុងការចូលរួមលើកស្ទួយ និងជំរុញការអនុវត្តសិទ្ធិ ការលើកកម្ពស់តួនាទីស្រ្តី ការវិនិយោគលើសមភាពយេនឌ័រ អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានដាក់ចេញនូវផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ**អ.ស.ហ.** សម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមខាងលើ។



# VI. ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុង

➢ ដើម្បីធានាឱ្យសម្រេចបានគោលបំណង និងគោលដៅខាងលើអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានដាក់ចេញនូវផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** សម្រាប់រយៈពេល ៣ ឆ្នាំ (២០២២-២០២៤) រួមមាន៖

*ក. ការកសាងរចនាសម្ព័ន្ធក្រុមការងារនារី។*

*ខ. ការបង្កើនចំនួនមន្ត្រីជាស្ត្រី។*

*គ. ការបង្កើនសមាសភាពថ្នាក់ដឹកនាំជាស្ត្រី។*





# VI. ផែនការសកម្មភាពយេនឌ័ររបស់អង្គភាពសវនកម្មផ្ទៃក្នុង (ត)

ឃ. ការបង្កើនការលើកទឹកចិត្តតាមរយៈការស្នើសុំផ្តល់គ្រឿងឥស្សរិយយស និងផ្តល់ប័ណ្ណសរសើរដល់មន្ត្រីជាស្ត្រី ដែលមានស្នាដៃក្នុងការបំពេញការងារ។

ង. ការអភិវឌ្ឍសមត្ថភាពមន្ត្រីតាមរយៈការផ្តល់ឱកាសទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញទាំងក្នុង និងក្រៅប្រទេស។

ច. ចូលរួមជាគ្រូឧទ្ទេសក្នុងការបណ្តុះបណ្តាលផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗដើម្បីបង្កើនភាពអង់អាចដល់ស្ត្រី។

ឆ. ការអភិវឌ្ឍកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយពាក់ព័ន្ធនឹងមុខងារសវនកម្មផ្ទៃក្នុងជូនសវនដ្ឋាន។



# សូមអរគុណ

# THANKS FOR YOUR ATTENTION



## អង្គភាពសវនកម្មផ្ទៃក្នុង
## INTERNAL AUDIT UNIT




Internal Audit Unit of Non-bank Financial Services Authority

អគារ ១៦៨F ជាន់ទី៩ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ